**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាចិនសិក្ខាសាលាមេក្រុមកាយឫទ្ធិ**
**ចំការទៀន ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩**

# យើងជាអ្នកបម្រើដែលមានចិត្តអត់ធ្មត់

**អត្ថបទទី១៖ សេរីភាព ១៧,៨-១៣**

លោកម៉ូសេពោលទៅកាន់លោកយ៉ូស៊ូអាថា៖ «ចូរជ្រើសរើសមនុស្សមួយចំនួន ហើយចេញទៅច្បាំងជាមួយជនជាតិអាម៉ាឡេកចុះ ស្អែកខ្ញុំនឹងឡើងទៅឈរលើកំពូលភ្នំ ទាំងកាន់ដំបងរបស់ព្រះជាម្ចាស់»។ សរ ១៧,៩

**អត្ថបទទី២៖ ធីម៉ូថេទី២ ៣,១៤-៤,២**

គ្រប់អត្ថបទគម្ពីរ សុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺឲ្យតែង និងមានប្រយោជន៍សម្រាប់បង្រៀន រកខុសត្រូវ កែតម្រង់ និងអប់រំឲ្យរស់តាមសេចក្ដីសុចរិត។ ២ធម ៤,១៦

**ដំណឹងល្អ៖ លូកា ១៨,១-៨**

ចំណង់បើព្រះជាម្ចាស់វិញ ព្រះអង្គរឹតតែរកយុត្តិធម៌ឲ្យអស់អ្នក ដែលព្រះអង្គបានជ្រើសរើស ហើយដែលអង្វរព្រះអង្គ ទាំងយប់ ទាំងថ្ងៃ ព្រះអង្គគ្រាន់តែបង្អង់បុ៉ណ្ណោះ។ លក ១៨,៧

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ព្រះសហគមន៍ណែនាំឲ្យយើងអធិដ្ឋាន ឲ្យយើងនឹកឃើញតួនាទីរបស់យើងជាគ្រីស្តបរិស័ទប្រកាសដំណឹងល្អ។ អត្ថបទទីពីរ "**យើងត្រូវតែប្រកាសដំណឹងល្អជានិច្ច**" នេះជាតួនាទីរបស់យើងជាគ្រីស្តបរិស័ទ។ សម្រាប់ប្អូនៗដែលជាមេក្រុមកាយឫទ្ធិ ដែលជាអ្នកណែនាំកូនៗកាយឫទ្ធិត្រូវការគិតពិចារណា **តើយើងអាចប្រកាសដំណឹងល្អរបៀបណា នៅក្នុងតួនាទីរបស់យើងជាមេក្រុមកាយឫទ្ធិ?** មិនមែនតែនិយាយអំពីព្រះយេស៊ូ អ្វីដែលសំខាន់បំផុតដូចសម្ដេចប៉ាបប៉ោឡូទី៦ បានរំលឹកឲ្យយើង "**យើងនឹងប្រកាសដំណឹងល្អនៅពេលយើងផ្ដល់សក្ខីភាព សក្ខីភាពមានតម្លៃលើសអ្វីៗទាំងអស់នៅលើផែនដីនេះ**"។ ពេលយើងមានសក្ខីភាពអំពីព្រះយេស៊ូ យើងដឹងថាយើងធ្វើដូចម្ដេចដើម្បីរស់នៅ នៅក្នុងទំនាក់ទំនងរបស់យើងជាប្រចាំថ្ងៃ ជាសាវ័ករបស់ព្រះយេស៊ូដោយចេះស្រឡាញ់គ្នាទៅវិញទៅមក។

សព្វថ្ងៃ ផែនដីរបស់យើងសុទ្ធតែសង្គ្រាម មនុស្សយើងមិនចេះសហការគ្នា មនុស្សមិនចេះសម្រុះសម្រួលគ្នា មនុស្សចេះតែច្រណែន ចេះតែអំនួត ចេះតែអាត្មានិយម...។ ប៉ុន្តែព្រះយេស៊ូបានណែនាំឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក ដូច្នេះសក្ខីភាពទីមួយដែលយើងត្រូវតែផ្ដល់នៅក្នុងជីវិតរបស់យើងប្រចាំថ្ងៃគឺ ដោយនឹកឃើញព្រះយេស៊ូស្រឡាញ់យើង ឲ្យយើងធ្វើដូចម្ដេចដើម្បីស្រឡាញ់គ្នាទៅវិញទៅមក។ ស្រឡាញ់គ្នាទៅវិញទៅមកមិនស្រួលទេ គ្រប់ទីកន្លែងដែល

យើងនៅពីមួយថ្ងៃទៅមួយថ្ងៃតែមានបញ្ហា មានមនុស្សដែលអន់ចិត្ត ដែលច្រណែន ដែលមើលងាយ...។ ដូច្នេះ យើងធ្វើដូចម្តេចដើម្បីផ្តល់សក្ខីភាពហ្នឹង មានតែសក្ខីភាពដែលណែនាំឲ្យមនុស្សឯទៀតៗ អាចមើលឃើញព្រះយេស៊ូនៅក្នុងជីវិតរបស់យើង ដែលនេះជារបៀបដើម្បីប្រកាសដំណឹងល្អ។

សម្រាប់យើងដែលជាមេក្រុមកាយឫទ្ធិ សូមយកអត្ថបទទីពីរធ្វើជាគោលយ៉ាងពិសេសដើម្បីពិចារណា ដោយសារមេក្រុមកាយឫទ្ធិត្រូវតែទទួលការអប់រំមុនអប់រំកូនក្មេង។ បើយើងមិនដែលបានទទួលការអប់រំ យើងធ្វើដូចម្តេចដើម្បីអប់រំបន្ត "**គ្រប់អត្ថបទគម្ពីរសុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺឲ្យតែង**" យើងអាចនិយាយថាគ្រប់មេរៀនដែលយើងបានទទួល គឺជាមេរៀនដើម្បីបំភ្លឺយើងជាប្រយោជន៍ដើម្បីបង្រៀនរកខុសត្រូវ កែតម្រង់ អប់រំ ឲ្យរស់នៅតាមសេចក្តីសុចរិតនៅក្នុងគោលបំណងឲ្យយើងទៅជាអ្នកបម្រើរបស់ព្រះជាម្ចាស់។ យើងមានពាក្យបួនដែលសំខាន់សម្រាប់យើងកំពុងទទួលការអប់រំ គឺះ

**ទីមួយ ឲ្យយើងចេះទទួលខុសត្រូវ** ពេលយើងធ្វើជាមេគេឲ្យយើងចេះទទួលខុសត្រូវលើការងារដែលយើងបានទទួល និងលើក្រុមដែលយើងទទួលនោះដែរ។

**ទីពីរ ឲ្យយើងចេះកែតម្រង់** កុំឲ្យយើងគិតថាយើងជាមនុស្សអស្ចារ្យដែលចេះទាំងអស់ ឲ្យយើងកែអាកប្បកិរិយា កែចិត្តគំនិត កែរបៀប ដោយនឹកឃើញព្រះជាម្ចាស់ស្រឡាញ់យើងយ៉ាងណា ឲ្យយើងស្រឡាញ់បងប្អូនយ៉ាងនោះដែរ។

**ទីបី អប់រំឲ្យរស់តាមសេចក្តីសុចរិត** ការអប់រំរបស់យើងណែនាំឲ្យយើងរស់នៅក្នុងភាពសុចរិត ចំពោះភាពអយុត្តិធម៌ ភាពទុចរិតឲ្យនៅឆ្ងាយពីយើង។ យើងធ្វើដូចម្តេចដើម្បីរកយុត្តិធម៌ យើងធ្វើដូចម្តេចដើម្បីរស់នៅក្នុងភាពសុចរិត ដែលមានចិត្តស្មោះដើម្បីធ្វើជាអ្នកបម្រើរបស់ព្រះជាម្ចាស់។

**ទីបួន បម្រើ** នេះជាគំនិតកំពូល សម្រាប់យើងជាមេឲ្យធ្វើជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ពេលយើងឯកភាពធ្វើជាមេក្រុមកាយឫទ្ធិមានន័យថាយើងបានឯកភាពធ្វើជាអ្នកបម្រើរបស់ព្រះជាម្ចាស់។ ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ យើងបានទទួលការអប់រំដើម្បីដឹងខុសដឹងត្រូវ ដើម្បីកែតម្រង់ ដើម្បីអប់រំដោយរស់នៅក្នុងភាពសុចរិត ក្នុងគោលបំណងតែមួយធ្វើជាអ្នកបម្រើរបស់ព្រះជាម្ចាស់។ នេះជាឥរិយាបថរបស់យើងជាមេគេ បម្រើកូនក្មេង បម្រើយុវជន បម្រើព្រះសហគមន៍ បម្រើសង្គម។ ពេលយើងថា ត្រៀមជានិច្ចមានន័យថាយើងជាអ្នកបម្រើជានិច្ច មិនមែនជាមនុស្សខ្ជិល មិនមែនជាមនុស្សដែលគ្មានកម្លាំង...។

នៅពេលយើងទៅតាមព្រះសហាគមន៍យើងវិញ សុំទៅជួបជាមួយលោកបូជាចារ្យដែលទទួលខុសត្រូវព្រះសហាគមន៍យើង ដើម្បីឲ្យលោកបូជាចារ្យ ឬបងប្រុសបងស្រីជម្រុញឲ្យកម្មវិធីកាយឫទ្ធិនៅក្នុងព្រះសហាគមន៍យើងមានជីវិត។ ទៅជួបជាមួយលោកបូជាចារ្យ ឬបងប្រុសបងស្រី ដើម្បីរិះគិត ឆ្នាំយើងត្រូវប្រជុំមួយខែម្ដងដើម្បីរៀបចំមេរៀនសម្រាប់អប់រំកូនក្មេងកាយឫទ្ធិតាមព្រះសហាគមន៍យើង ដោយមានវត្តមានលោកបូជាចារ្យ ឬបងប្រុសបងស្រីចូលរួម។ ដូចអត្ថបទគម្ពីរដំណឹងល្អដែលយើងស្ដាប់ថ្ងៃនេះ មានយាយម្នាក់ដែលបានសុំឲ្យចៅក្រមរកយុត្តិធម៌ឲ្យគាត់ ម្ដងហើយម្ដងទៀតរហូតចៅក្រមព្រមរកយុត្តិធម៌ឲ្យគាត់។ ឲ្យយើងជួបជាមួយលោកបូជាចារ្យ ឬបងប្រុសបងស្រី កុំឲ្យកម្មវិធីកាយឫទ្ធិរបស់យើងទៅជាកម្មវិធីមួយដែលគ្មានន័យ។

ចូររៀបចំមេរៀននិងណែនាំក្មេងៗឲ្យគេចូលនៅក្នុងជីវិតជាកាយឫទ្ធិ ដោយចេះស្រឡាញ់ធម្មជាតិ ចេះគោរពចាស់ទុំ ចេះគោរពសង្គមជាតិ ចេះគោរពសាសនា មានចិត្តមេត្តាករុណា...។ ក្នុងអត្ថបទទីពីរ "**ព្រមទាំងនិយាយហើយនិយាយទៀត ទូន្មានក្នុងឱកាសល្អក្ដីមិនល្អក្ដី ត្រូវពន្យល់គេឲ្យដឹងខុសត្រូវ ស្ដីបន្ទោសដាស់តឿន និងបង្រៀនគេដោយចិត្តអត់ធ្មត់គ្រប់ជំពូក**"។ យើងត្រូវតែពន្យល់គេឲ្យដឹងខុសត្រូវ ស្ដីបន្ទោសយើងមិនថាល្អទាំងដែលគេធ្វើមិនល្អនោះទេ នេះជាតួនាទីរបស់យើង។ សព្វថ្ងៃ ឪពុកម្ដាយពេលកូនយំឲ្យទូរស័ព្ទទៅកូនលេង ពេលកូនសុំនេះសុំនោះឲ្យភ្លាម មិនបានពន្យល់ណែនាំកូនសោះ។ ដាស់តឿន នេះជាតួនាទីរបស់យើង ប៉ុន្តែមិនមែនដាស់តឿនណែនាំឲ្យគេអស់សង្ឃឹមនោះទេ ដាស់តឿនកូនៗរបស់យើងដើម្បីឲ្យគេរីកចម្រើននៅក្នុងសេចក្ដីស្រឡាញ់ រីកចម្រើននៅក្នុងការសហការគ្នា រីកចម្រើននៅក្នុងការចេះថែរក្សានិងស្រឡាញ់ធម្មជាតិ ស្រឡាញ់ព្រះជាម្ចាស់ ស្រឡាញ់ចាស់ទុំ ស្រឡាញ់ឪពុកម្ដាយ និងស្រឡាញ់សង្គមជាតិរបស់គេ។ បង្រៀនគេពីមួយសប្ដាហ៍ទៅមួយសប្ដាហ៍ ដោយចិត្តអត់ធ្មត់គ្រប់ជំពូក ដូចព្រះជាម្ចាស់ដែលបានតស៊ូជាមួយមនុស្សយើង។ ប៉ុន្មានដងយើងធ្វើខុស ប៉ុន្មានដងយើងនៅឆ្ងាយពីព្រះអង្គ ប៉ុន្តែព្រះអង្គនៅតែស្វាគមន៍យើងជានិច្ច។

យើងជាមេក្រុមកាយឫទ្ធិគឺ យើងជាអ្នកបម្រើកូនក្មេង ដោយណែនាំកូនក្មេងរបស់យើងដោយមានចិត្តអត់ធ្មត់ និងសុំឲ្យលោកបូជាចារ្យ ឬបងប្រុសបងស្រីចូលរួមប្រជុំមួយខែម្ដងជាមួយយើងដែលជាមេក្រុមកាយឫទ្ធិ។ ពេលយើងបាត់កូនក្មេងនៅក្នុងកម្មវិធីកាយឫទ្ធិរបស់យើង មិនមែនដោយសារកូនក្មេងគេរវល់ សំខាន់គឺកម្មវិធីរបស់យើងមិនណែនាំឲ្យគេមានសេចក្ដីសុខនិងអំណរសប្បាយ។ គេមកដោយសារគេរកឃើញបងប្អូនដែលចេះស្រឡាញ់ ចេះលើកទឹកចិត្ត ចេះផ្ដល់កម្លាំងកាយកម្លាំងចិត្តឲ្យគេ ដោយណែនាំឲ្យគេសប្បាយចិត្តជាមួយយើងក្នុងកម្មវិធីកាយឫទ្ធិរបស់យើង កាយឫទ្ធិ គឺត្រៀមជានិច្ច។ អាម៉ែន៕